NAGOMi
National Association for Global & Open Minded Communities

一般財団法人 外国人材共生支援全国協会
National Association for Global & Open Minded Communities

# ប្រព័ន្ធពលករជំនាញជនជាតិបរទេស

## យុទ្ធនាការលុបបំបាត់ទង្វើរខុសច្បាប់

### ស្ថាប័នផ្តល់ជំនួយ

- ☐ បង្កើតទំនាក់ទំនងឱ្យបានច្បាស់លាស់ជាមួយធនធានមនុស្សបរទេសដែលជាគោលដៅនៃការផ្តល់ជំនួយគាំពារ ។
- ☐ ធ្វើការពិគ្រោះជាទៀងទាត់ "ទល់មុខគ្នា" ដោយប្រើភាសាដែលអាចយល់បាន។
- ☐ ពិនិត្យមើលថ្លៃសេវាមិនសមរម្យ, ប្រាក់កម្ចីដែលខ្ពស់, ប្រាក់អំណោយដែលលើស
- ☐ ពិនិត្យមើលថាតើមានសកម្មភាពក្លែងបន្លំដោយស្ថាប័នទទួលពលករដែរឬទេ។

### ស្ថាប័នទទួលពលករជំនាញ

- ☐ ផ្តល់ការពន្យល់ល្អិតល្អន់អំពីលក្ខខណ្ឌការងារ,ការចំណាយលើការកាត់កងនិងបរិដ្ឋានការងារ ជីវភាពរស់នៅ។
- ☐ បញ្ឈប់ការរើសអើងលើជនបរទេស
- ☐ បញ្ឈប់ការជ្រើសរើសតាមរយៈមេខ្យល់ខុសច្បាប់
- ☐ កត់ត្រាឱ្យបានត្រឹមត្រូវ និងបញ្ជូនឯកសារទាក់ទងនឹងស្ថានភាពទទួលយក និងស្ថានភាពសកម្មភាពរបស់ពលករ។
- ☐ អនុវត្តតាមច្បាប់ស្តង់ដារការងារយ៉ាងតឹងរ៉ឹង
- ☐ អនុវត្តតាមច្បាប់ដែលធានាសុវត្ថិភាព និងសុខភាពរបស់ពលករអោយបានតឹងរ៉ឹង

### ជនបរទេសដែលជាពលករជំនាញ

- ☐ យល់ច្បាស់អំពីលក្ខខណ្ឌការងារ (ខ្លឹមសារការងារ) ការចំណាយដែលអាចកាត់កងបាន ស្ថានភាពការងារនិង ការរស់នៅ។
- ☐ បង្កើតមុខរបរផ្ទាល់ខ្លួនសម្រាប់អនាគត
- ☐ ការពារខ្លួនដោយខ្លួនឯង និងអនុវត្តតាមច្បាប់ពាក់ព័ន្ធ និងវិន័យក្នុងសង្គម

### ស្ថាប័នបញ្ជូន

- ☐ ជៀសវាងការទទួលភ្ញៀវច្រើនជ្រុល ការសូកលុយទៅស្ថាប័នទទួល និងស្ថាប័នផ្តល់ជំនួយ។
- ☐ សូមរក្សាកម្រៃជើងសារដែលប្រមូលពីពលករជំនាញជនបរទេសក្នុងចំនួនដែលស្របច្បាប់។



ប្រព័ន្ធពលករជំនាញជនជាតិបរទេស
2024
យុទ្ធនាការលុបបំបាត់ទង្វើរខុសច្បាប់

外務省 Ministry of Foreign Affairs of Japan
ひと、くらし、みらいのために 厚生労働省 Ministry of Health, Labour and Welfare
法務省 MINISTRY OF JUSTICE
経済産業省 Ministry of Economy, Trade and Industry
MAFF 農林水産省
国土交通省 Ministry of Land, Infrastructure, Transport and Tourism

NAGOMi
National Association for Global & Open Minded Communities

一般財団法人 外国人材共生支援全国協会
National Association for Global & Open Minded Communities

# ប្រព័ន្ធពលករជំនាញជនជាតិបរទេស

## យុទ្ធនាការលុបបំបាត់ទង្វើរខុសច្បាប់

### ស្ថាបន័ផ្តល់ជំនួយ

**01. បង្កើតទំនាក់ទំនងឱ្យបានច្បាស់លាស់ជាមួយធនធានមនុស្សបរទេសដែលជាគោលដៅនៃការផ្តល់ជំនួយគាំពារ ។**

- អាចពឹងផ្អែកបានមិនត្រឹមតែក្នុងជីវិតប្រចាំថ្ងៃប៉ុណ្ណោះទេប៉ុន្តែថែមទាំងក្នុងគ្រាលំបាកផងដែរ។
- ធានាបានថាមានអ្នកបកប្រែពេញម៉ោងដែលអាចទាក់ទងពួកគេភ្លាមៗនៅពេលមានបញ្ហាកើតឡើង។

**02. ធ្វើការពិគ្រោះជាទៀងទាត់ "ទល់មុខគ្នា" ដោយប្រើភាសាដែលអាចយល់បាន។**

- ការពិគ្រោះដោយទៀងទាត់ជាមួយជនបរទេសដែលជាពលករជំនាញ និងអ្នកគ្រប់គ្រងរបស់ពួកគេ ជាគោលការណ៍ត្រូវធ្វើឡើងរៀងរាល់បីខែម្តងក្នុងលក្ខណៈនិយាយទល់មុខ និងប្រើភាសាដែលអាចយល់គ្នាបាន។

**03. ពិនិត្យមើលថ្លៃសេវាមិនសមរម្យ, ប្រាក់កម្ចីដែលខ្ពស់, ប្រាក់អំណោយដែលលើស**

- ពិនិត្យមើលថាតើមានការយកកម្រៃសេវាប្រាក់ធានាប្រាក់ផាកពិន័យជាដើមដែលមិនត្រូវបានអនុញ្ញាតឱ្យប្រមូលពីពលករជំនាញជនបរទេស
- ដែលធ្វើឱ្យសមីបុគ្គលទទួលរងនូវបន្ទុកបំណុលច្រើន។

**04. ពិនិត្យមើលថាតើមានសកម្មភាពក្លែងបន្លំដោយស្ថាបន័ទទួលពលករដែរឬទេ។**

- តាមរយៈការសម្ភាសន៍ ការពិគ្រោះយោបល់ទៀងទាត់ និងឆ្លងកាត់ការទទួលបណ្តឹង ត្រូវពិនិត្យមើលថាតើមានការរំលោភលើច្បាប់និងបទប្បញ្ញត្តិដូចជាច្បាប់ទាក់ទងនឹងការងារ និងច្បាប់អន្តោប្រវេសន៍បង្កឡើងដោយស្ថាបន័ទទួលពលករជំនាញ ឬថាតើមានការប្រព្រឹត្តខុសផ្សេងទៀតដូចជាការដកហូតលិខិតឆ្លងដែននិងប័ណ្ណស្នាក់នៅ ដែរឬទេ ហើយត្រូវរាយការណ៍ទៅស្ថាប័នពាក់ព័ន្ធ ប្រសិនបើមានបញ្ហានោះកើតឡើង។

### ស្ថាបន័ទទួលពលករជំនាញ

**05. ផ្តល់ការពន្យល់ល្អិតល្អន់អំពីលក្ខខណ្ឌការងារ,ការចំណាយលើការកាត់កង និងបរិដ្ឋានការងារ ជីវភាពរស់នៅ។**

- ពន្យល់ឱ្យបានហ្មត់ចត់អំពីចំនួនទឹកប្រាក់ និងខ្ទង់ចំណាយលម្អិតស្តីអំពីលក្ខខណ្ឌការងារសម្រាប់ពលករជំនាញជនបរទេស (ជាពិសេសប្រាក់ថែមម៉ោង និងប្រាក់រង្វាន់) ការចំណាយដែលបានបង់ទៅឱ្យស្ថាប័នទទួលពលករជំនាញ ដូចជាការចំណាយជាប្រចាំ (ថ្លៃផ្ទះ ថ្លៃម្ហូបអាហារ ។ល។)។
- រួមបញ្ចូលទាំងបរិដ្ឋានការងារ ការរស់នៅ ត្រូវពន្យល់ពីទុកជាមុនជាភាសាកំណើត ក្នុងករណីដែលពលករជំនាញជនជាតិបរទេសត្រូវទទួលបន្ទុកបង់ ឬផ្តល់សំណង ហើយកត់ត្រាសំណួរនិងចម្លើយបើមាន។

**06. បញ្ឈប់ការរើសអើងលើជនបរទេស**

- បញ្ឈប់ការរើសអើងដោយផ្អែកលើហេតុផលថាជាជនបរទេស ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃប្រាក់ឈ្នួល ការអប់រំ អត្ថប្រយោជន៍សុខុមាលភាព។ល។
- ជៀសវាងការបណ្តេញចេញពីការងារ ឬការព្យាបាលដែលមិនសមស្របដោយសារការបញ្ឈប់នូវការបណ្តេញចេញពីការងារឬការប្រើដោយមិនទទួលបានប្រយោជន៍ក្រោមហេតុផល មានផ្ទៃពោះ ការសម្រាលកូន របួសស្នាម មានជំងឺជាដើម០ម្យ៉ាងទៀត ការឈប់សម្រាកមើលថែកូនគឺជាសិទ្ធិរបស់ពលករជំនាញទាំងអស់ ដោយមិនថាពួកគេជាបុរសឬស្រ្តីនោះទេ។)
- សូមបញ្ឈប់អំពើហឹង្សា ភាសាប្រមាថ ការគម្រាមកំហែង ការយាយី ការបង្ខំឱ្យត្រឡប់ទៅប្រទេសវិញនិងការរឹតត្បិតមិនសមហេតុផលចំពោះសេរីភាពនៃជីវិតឯកជនរបស់ពលករជំនាញ។

**07. បញ្ឈប់ការជ្រើសរើសតាមរយៈមេខ្យល់ខុសច្បាប់**

- ធ្វើយ៉ាងណាកុំអោយលុយបានទៅដល់ម្ចាស់អាជីវកម្ម (រួមទាំងបុគ្គល) ដែលគ្មានអាជ្ញាប័ណ្ណបញ្ជូនទៅក្រៅប្រទេសនិងអ្នកម្ចាស់អាជីវកម្មណែនាំការងារដែលមិនមានអាជ្ញាប័ណ្ណអនុញ្ញាតក្នុងប្រទេសជប៉ុន។
- ពិនិត្យមើលថាតើថ្លៃសេវា រួមទាំងការទូទាត់ទៅឱ្យឈ្មួញកណ្តាល លើសពីដែនកំណត់ច្បាប់ដែរឬទេ។

**08. កត់ត្រាឱ្យបានត្រឹមត្រូវ និងបញ្ជូនឯកសារទាក់ទងនឹងស្ថានភាពទទួលយក និងស្ថានភាពសកម្មភាពរបស់ពលករ។**

- បង្កើត និងរក្សាកំណត់ត្រាគ្រប់គ្រងផ្សេងៗ បញ្ជូនការជូនដំណឹងប្រចាំត្រីមាសអំពីស្ថានភាពនៃការទទួលនិងសកម្មភាពរបស់ពកលករជំនាញជនបរទេសនិងប្រកាន់ខ្ជាប់នូវកាលបរិច្ឆេទនៃការជូនដំណឹងនៅពេលផ្លាស់ប្តូរកិច្ចសន្យា ពេលជួបការលំបាក និងនៅពេលកិច្ចសន្យាបញ្ចប់។

**09. អនុវត្តតាមច្បាប់ស្តង់ដារការងារយ៉ាងតឹងរ៉ឹង**

- ត្រូវប្រាកដថាបង់ថ្លៃឈ្នួលសមរម្យ (ជាពិសេសប្រាក់ឈ្នួលថែមម៉ោង និងការងារនៅថ្ងៃសម្រាក)
- ជៀសវាងការងារថែមម៉ោងខុសច្បាប់ (ពិនិត្យមើលថាតើការងារបន្ថែមម៉ោង និងម៉ោងធ្វើការក្នុងថ្ងៃឈប់សម្រាកស្ថិតក្នុងកម្រិតដែលបានព្រមព្រៀងគ្នាដែរឬទេ)
- ត្រូវទទួលបានការឈប់សម្រាកដែលទទួលបានប្រាក់ខែប្រចាំឆ្នាំ ( 5 ថ្ងៃក្នុងមួយឆ្នាំ)
- ត្រូវរក្សាទុកសៀវភៅច្បាប់ចំនួន៤ (សៀវភៅបញ្ជីប្រាក់ឈ្នួល សៀវភៅវត្តមាន បញ្ជីឈ្មោះពលករ សៀវភៅគ្រប់គ្រងការឈប់សម្រាកទទួលបានប្រាក់ឈ្នួលប្រចាំឆ្នាំ)
- ផ្តល់កន្លែងស្នាក់នៅប្រកបដោយសុវត្ថិភាព និងអនាម័យ

**10. អនុវត្តតាមច្បាប់ដែលធានាសុវត្ថិភាព និងសុខភាពរបស់ពលករអោយបានតឹងរ៉ឹង**

- បង្កើតប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាព (ការតែងតាំងអ្នកគ្រប់គ្រងសុវត្ថិភាព អ្នកគ្រប់គ្រងសុខភាព ប្រធានការងារ។ល។)
- ពន្យល់ខ្លឹមសារការងារ និងស្ថានភាពការងារឱ្យងាយយល់ ក្នុងពេលសម្ភាសន៍ ពេលចុះកិច្ចសន្យាការងារ និងពេលចូលធ្វើការ។
- ផ្តល់ការអប់រំអំពីសុវត្ថិភាព និងសុខភាពឱ្យបានហ្មត់ចត់ (ការអប់រំនៅពេលទទួលអោយធ្វើការ ឬផ្លាស់ប្តូខ្លឹមសារការងារ ការអប់រំពិសេសទាក់ទងនឹងគ្រោះថ្នាក់ការងារ ការអប់រំសុវត្ថិភាព និងសុខភាព)។
- ធានាថាពលករជំនាញទទួលយកវគ្គសិក្សាជំនាញ និងការអប់រំពិសេស និងទទួលបានសញ្ញាបត្រ័ទាក់ទងនឹងការងារ។
- ត្រូវប្រាកដថាធ្វើការត្រួតពិនិត្យសុខភាពជាប្រចាំពិនិត្យករណីចាំបាច់ណាមួយនិងពិនិត្យមើលភាពតានតឹងរបស់ពលករជំនាញជនបរទេស ។
- ក្នុងករណីមានឧបទ្ទវហេតុ ឬរបួសទាក់ទងនឹងការងារ សូមកុំលាក់បាំង ត្រូវរាយការណ៍។

### ជនបរទេសដែលជាពលករជំនាញ

**11. យល់ច្បាស់អំពីលក្ខខណ្ឌការងារ (ខ្លឹមសារការងារ) ការចំណាយដែលអាចកាត់កងបាន ស្ថានភាពការងារនិង ការរស់នៅ។**

- ប្រសិនបើមានអ្វីដែលមិនយល់ ត្រូវតែពិភាក្សា។

**12. បង្កើតមុខរបរផ្ទាល់ខ្លួនសម្រាប់អនាគត**

- ធ្វើការជារៀងរាល់ថ្ងៃបណ្តើរហើយពិគ្រោះយោបល់ជាមួយអ្នកជុំវិញខ្លួននូវអ្វីដែលអ្នកចង់ធ្វើ
- ត្រូវមានគោលដៅដើម្បីទទួលបានជំនាញភាសាជប៉ុន និងជំនាញជាក់លាក់ ។

**13. ការពារខ្លួនដោយខ្លួនឯង និងអនុវត្តតាមច្បាប់ពាក់ព័ន្ធ និងវិន័យក្នុងសង្គម**

- នៅពេលគិតអំពីការផ្លាស់ប្តូរការងារ ត្រូវពិគ្រោះជាមួយអ្នកជុំវិញខ្លួនសិនអំពីស្ថានភាពបច្ចុប្បន្ន និង ការដែលអាចធ្វើឱ្យមានភាពប្រសើរឡើង។
- កុំបារម្ភតែម្នាក់ឯងត្រូវពិភាក្សាជាមួយអ្នកដ៏ទៃថាអ្នកកំពុងត្រូវបានបោកប្រាស់ឬកេងចំណេញពីអ្នកណែនាំអ្នកឱ្យធ្វើការដែលឬអត់ ។
- សូមគោរពតាមច្បាប់ពាក់ព័ន្ធ និងវិន័យក្នុងសង្គម ដោយមិនគិតតែផលប្រយោជន៍ផ្ទាល់ខ្លួននិងមិនចូលរួមក្នុងអំពើឧក្រិដ្ឋ ឬបង្កគ្រោះថ្នាក់។

### ស្ថាបន័បញ្ជូន

**14. ជៀសវាងការទទួលភ្ញៀវច្រើនជ្រុល ការសូកលុយទៅស្ថាបន័ទទួល និងស្ថាបន័ផ្តល់ជំនួយ។**

**15. សូមរក្សាកម្រៃជើងសារដែលប្រមូលពីពលករជំនាញជនបរទេសក្នុងចំនួនដែលស្របច្បាប់។**

- គោរពតាមច្បាប់ និងបទប្បញ្ញត្តិ ដូចជាការរក្សាកម្រៃជើងសារដែលប្រមូលពីពលករជំនាញជនបរទេសក្នុងដែនកំណត់ច្បាដោយប់។
- ចេញវិក្កយប័ត្រផ្លូវការ និងបញ្ជាក់ពីចំនួនទឹកប្រាក់ដែលត្រូវបង់ដោយពលករជំនាញជនបរទេសអោយបានច្បាស់លាស់ ។